00406196



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30/11/2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/២០-១០-២០០៩-អវតក/[illegible]

អង្គបុរេជំនុំជម្រះ

ចំពោះមុខៈ
ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ន័យ ថុល
ចៅក្រម Florence MUMBA
ចៅក្រម ហួត វុទ្ធី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 01/DEC/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fuy

កាលបរិច្ឆេទៈ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

---

សាធារណៈ

**សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឲ្យមានវិធានការសមស្របពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើដោយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រម អង្គបុរេជំនុំជម្រះ ចៅក្រម Katinka LAHUIS និងចៅក្រម Rowan DOWNING**

---

**សហព្រះរាជអាជ្ញា**
ជា លាង
William SMITH

**ជនត្រូវចោទ**
អៀង សារី

**ចៅក្រមអន្តរជាតិអង្គបុរេជំនុំជម្រះ**
Rowan DOWNING
Katinka LAHUIS

**សហមេធាវីការពារក្តីជនត្រូវចោទ**
អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ * E.C.C.C. * C.E.T.C. * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

០០២/២០-១០-២០០៨-អវតក/កសចស (អបជ ០៣)

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**")

**បានទទួល**"សំណើសុំឲ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួនដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ លោកស្រីចៅក្រម Katinka LAHUIS និង លោកចៅក្រម Rowan DOWNING" របស់មេធាវីការពារក្តី ដែលបានដាក់កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ អនុលោមតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង និងបានជូនដំណឹងកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ("សំណើសុំ")។

**បានឃើញ** អនុស្សរណៈរបស់ប្រធានអង្គបុរេជំនុំជម្រះ ប្រាក់ គឹមសាន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ផ្ញើជូនគណៈកម្មាធិការរដ្ឋបាលតុលាការ ("JAC") ដែលបានណែនាំអំពីការតែងតាំងចៅក្រមបំរុងអន្តរជាតិរបស់អង្គបុរេជំនុំជម្រះ ជូនអង្គបុរេជំនុំជម្រះ ក្នុងគោលបំណងដើម្បីធ្វើការសម្រេចលើសំណើសុំ និងបានស្នើឲ្យ JAC ធ្វើការតែងតាំងចៅក្រមអន្តរជាតិបន្ថែមមួយរូបទៀត ក្នុងគោលបំណងនេះ អនុលោមតាមវិធាន៣៤(៤) នៃវិធានផ្ទៃក្នុង។

**បានឃើញថែមទៀត** នូវសេចក្តីសម្រេចរបស់ JAC ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ ដែលបានតែងតាំងចៅក្រមអង្គជំនុំជម្រះសាលាដំបូងអន្តរជាតិ លោកចៅក្រម Jean-Marc LAVERGNE ជូនអង្គបុរេជំនុំជម្រះ ក្នុងគោលបំណងដើម្បីសម្រេចលើសំណើសុំ។

**បានទទួល** សារណាសម្ងាត់របស់លោកចៅក្រម Rowan Downing និងលោកស្រីចៅក្រម Katinka Lahuis អនុលោមតាមវិធាន៣៤(៧) នៃវិធានផ្ទៃក្នុង កាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៨។

**បានពិចារណា** លើ"ចម្លើយតបទៅនឹងពាក្យសុំឲ្យមានវិធានការសមរម្យរបស់ជនត្រូវចោទ អៀង សារី" របស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ" ដែលបានដាក់កាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ("ចម្លើយតប")។

## I. **សេចក្តីផ្តើម**

១. ផ្អែកតាមសេចក្តីថ្លែងការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថា "ចៅក្រមបរទេសមួយចំនួន[នៃអង្គជំនុំជម្រះវិសាមញ្ញ]គួរតែទទួល

បញ្ហាមកពីរដ្ឋាភិបាលរបស់ខ្លួន"[1] សំណើសុំបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ"ប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដែលមានរបស់ខ្លួន" ដើម្បីមាន"វិធានការដែលចាំបាច់ និងសមរម្យទាំងឡាយ ដើម្បីធ្វើការបំភ្លឺ និង/ឬត្រួតពិនិត្យមើលទង្វើ ដែលត្រូវបានចោទប្រកាន់មកលើលោកស្រីចៅក្រម Katinka Lahuis និងលោកចៅក្រម Rowan Downing"[2]។ ទោះបីជាសំណើសុំត្រូវបានដាក់ស្របតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង[3]ហើយក៏ដោយ ក៏សំណើសុំមិនបានសុំជំទាស់លោកចៅក្រម Downing និងលោកស្រីចៅក្រម Lahuis នោះទេ ក៏ប៉ុន្តែ សំណើបានសុំឱ្យមានវិធានការដែលមិនបានបញ្ជាក់ច្បាស់លាស់ទៅវិញ។ បន្ថែមពីលើនេះទៀត សំណើសុំនេះទាមទារនូវសេចក្តីសម្រេច ដែលត្រូវធ្វើឡើងយ៉ាងឆាប់រហ័សលើសំណើសុំ បន្ទាប់ពីមានសវនាការដេញដោលផ្ទាល់មាត់ធ្វើឡើងជាសាធារណៈ និងការព្យួរបញ្ហាដែលមិនទាន់សម្រេចផ្សេងៗទៀតទាំងអស់ នៅចំពោះមុខអង្គបុរេជំនុំជម្រះនៅចន្លោះពេលនេះសិន[4]។ នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាអះអាងថា សំណើសុំមិនអាចទទួលយកបានទេ ហើយសំណើសុំនេះក៏ខ្វះនូវអង្គសេចក្តី និងគ្មានភស្តុតាងបញ្ជាក់នោះដែរ[5]។

## II. ការពិចារណា

### ក. សំណើសុំបើកសវនាការជាសាធារណៈ និងព្យួរកិច្ចដំណើរការនីតិវិធី

២. វិធាន៣៤(៧) នៃវិធានផ្ទៃក្នុងបង្ហាញថា បណ្តឹងជំទាស់ជាមួយនឹងសារណានានា ដែលបានកំណត់ ស្របតាមអនុវិធាននេះ ត្រូវពិចារណាដោយចៅក្រមអង្គជំនុំជម្រះ ដែលចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ។ នីតិវិធីដែលបានរៀបរាប់នៅក្នុងវិធាន៣៤(៧) នៃវិធានផ្ទៃក្នុងកំណត់អំពីសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលធ្វើដោយអង្គជំនុំជម្រះ ផ្អែកតាម

---

[១] សំណើសុំ កថាខណ្ឌ៩។

[២] *ដូចខាងលើដែរ* កថាខណ្ឌ១៥។

[៣] *ដូចខាងលើដែរ* កថាខណ្ឌ១។

[៤] *ដូចខាងលើដែរ* ។

[៥] ចម្លើយតប កថាខណ្ឌ២៤-២៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បណ្តឹងជិតចិត្តនិងសារណាដែលធ្វើដោយចៅក្រមរូបនោះ។ វិធានផ្ទៃក្នុង មិនមានកំណត់អំពីសវនាការទេ។ អង្គបុរេជំនុំជម្រះ កាលពីលើកមុន បានយល់ឃើញថា នៅពេលដែលអង្គបុរេជំនុំជម្រះមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើការសម្រេចលើពាក្យបណ្តឹងនេះ ហើយដើម្បីផលប្រយោជន៍យុត្តិធម៌ ក្នុងការបន្តកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស អង្គបុរេជំនុំជម្រះអាចធ្វើការសម្រេចលើបញ្ហានេះ ដោយមិនចាំបាច់បើកសវនាការជាសាធារណៈនោះទេ[6]។ តុលាការអន្តរជាតិផ្សេងទៀត ក៏បានធ្វើការសម្រេចតាមទម្លាប់លើពាក្យបណ្តឹងស្រដៀងគ្នានេះដែរ ដោយគ្រាន់តែផ្អែកតាមកិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។ អង្គជំនុំជម្រះពិចារណាឃើញថា វាស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌ ក្នុងការដំណើរការឲ្យបានឆាប់រហ័ស និងក្នុងការសម្រេចលើសំណើសុំដោយមិនបើកសវនាការជាសាធារណៈ។ តម្លាភាព នៃកិច្ចដំណើរការនីតិវិធី នឹងត្រូវបានធានាតាមរយៈការចាត់ចំណាត់ថ្នាក់សារជាថ្មីលើការដាក់ឯកសារទាំងអស់ ដែលពាក់ព័ន្ធនឹងសំណើសុំនេះ ថាជាឯកសារសាធារណៈ។

៣. អនុលោមតាមវិធាន៣៤(៥) នៃវិធានផ្ទៃក្នុង បណ្តឹងជិតចិត្តមិនបង្អាក់កិច្ចដំណើរការនីតិវិធីនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចៅក្រមអាចលាលែងដោយស្ម័គ្រចិត្តបាន។ ទាក់ទិននឹងបញ្ហានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាលោកចៅក្រម Downing និងលោកស្រីចៅក្រម Lahuis ដកខ្លួនចេញពីការធ្វើសេចក្តីសម្រេចលើសំណើសុំនេះ និងត្រូវបានជំនួសវិញ ដូចមានចែងនៅក្នុងវិធាន៣៤ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ពួកគាត់មិនឯកភាពថា អង្គបុរេជំនុំជម្រះមិនត្រូវកំណត់សម្រេចលើបញ្ហាផ្សេងទៀតនោះទេ លុះត្រាតែសំណើសុំនេះត្រូវបានសម្រេចសិននោះ[7]។

ខ. <u>ទម្រង់នៃដំណោះស្រាយដែលបានស្នើសុំក្នុងសំណើ</u>

---

[6] សេចក្តីសម្រេច*លើករណីចៅក្រម ន័យ ថុល* កថាខណ្ឌ៨។ *Cf.* ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ និ ងពាក្យសុំនានាក្រោមអនុវិធាន៧៣(ក)-(គ) វិធាន៧៧(៣)(ខ) នៃវិធានផ្ទៃក្នុងផ្តល់អំណាចឲ្យអង្គជំនុំជម្រះសម្រេចលើពាក្យសុំដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីនានាតែប៉ុណ្ណោះ។

[7] សេចក្តីសន្និដ្ឋានរបស់ចៅក្រម Katinka Lahuis និង Rowan Downing កថាខណ្ឌ២។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

៤. វិធាន៣៤(២) នៃវិធានផ្ទៃក្នុងចែងថា "ភាគីអាចធ្វើបណ្តឹងជំទាស់ចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយ ដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលំអៀង"។ យោងតាមវិធាន៣៤(៣)នៃវិធានផ្ទៃក្នុង ការអនុវត្តបែបនេះ "ត្រូវបង្ហាញឲ្យច្បាស់លាស់ អំពីមូលហេតុ នៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ"។

៥. យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញ និងតុលាការអន្តរជាតិផ្សេងទៀតបានលើកឡើងស្របគ្នាថា លក្ខខណ្ឌកំណត់នៃភាពអនាគតិត្រូវបានរំលោភបំពាន ទាំងនៅពេលដែលចៅក្រមមានភាពលំអៀងជាក់ស្តែងផង ទាំងនៅពេលដែលគ្រាន់តែមានអាការៈទំនងថាមានភាពលំអៀងផង[៨]។ អាការៈទំនងថាមានភាពលំអៀង កើតមានឡើងក្នុងករណីដែល (ក) ចៅក្រមគឺជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផលប្រយោជន៍ជាកម្មសិទ្ធិនៅក្នុងលទ្ធផលនៃរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះនឹងនាំឲ្យមានការឡើងកម្រិត នៃបុព្វហេតុមួយដែលគាត់មានការពាក់ព័ន្ធជាមួយ ឬក៏ (ខ)កាលៈទេសៈនានានឹងនាំឲ្យមានអ្នកសង្កេតការណ៍ដ៏សមហេតុផល យល់ដឹងបាន ប្រកបដោយភាពសមហេតុផលថា មានភាពលំអៀងនៅពេលខ្លួនទទួលបានព័ត៌មានត្រឹមត្រូវ[៩]។

៦. អ្នកសង្កេតការណ៍ដ៏សមហេតុផល ក្នុងការវាយតម្លៃអំពីភាពលំអៀងនេះ គឺត្រូវតែជា"បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់ យល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំង ប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពមិនលំអៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផង ដែលថា ភាពអនាគតិ គឺជាករណីយកិច្ចមួយក្នុងចំណោម

---

[៨] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Furundzija* សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿងលេខ IT-95-17/1-A ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២000 កថាខណ្ឌ១៨១-៨៨ ("សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល *Furundzija*")។

[៩] *ដូចខាងលើដែរ* កថាខណ្ឌ១៨៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.T.C.

ករណីយកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រលើកតម្កើងឡើង"[10]។ ដូច ដែលបានឃើញនៅក្នុងយុត្តិសាស្ត្រមុនៗ របស់អង្គជំនុំជម្រះវិសាមញ្ញរួចហើយ ចំណុច ចាប់ផ្ដើមសម្រាប់ ធ្វើការកំណត់សម្រេចអំពីការចោទប្រកាន់ពីភាពលំអៀង គឺជាការសន្មត ទុកជាមុន អំពីភាពអនាគតិ ដែលមានចំពោះចៅក្រមអង្គជំនុំជម្រះវិសាមញ្ញ ដែលបានផ្អែកលើ ការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រម និងលក្ខណៈសម្បត្តិនានាសម្រាប់ ការតែងតាំងពួកគាត់[11]។

៧. ភាគីដែលដាក់ពាក្យបណ្ដឹង មានបន្ទុកដកចេញ នូវការសន្មតទុកជាមុននោះដែលជាចំណុច ចាប់ផ្ដើមយ៉ាងខ្ពស់មួយ[12]។ មូលហេតុនៃចំណុចចាប់ផ្ដើមដ៏ខ្ពស់នេះ គឺថាខណៈពេលដែលភាព លំអៀងពិតប្រាកដ ឬអាចមើលឃើញលើផ្នែកមួយរបស់ចៅក្រមណាម្នាក់ វាប៉ះពាល់ដល់ ភាពសម្ងាត់ នៃកិច្ចការរដ្ឋបាល វានឹងស្មើនឹងការគំរាមកំហែងលើផលប្រយោជន៍នៃកិច្ចការ រដ្ឋបាលដែលមិនលំអៀង និងយុត្តិធម៌ ប្រសិនបើចៅក្រមមានគុណសម្បត្តិគ្រប់គ្រាន់ផ្អែក

---

[១០] *ដូចខាងលើដែរ* កថាខណ្ឌ១៩០។

[១១] *សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល* ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៨ ('សេចក្ដីសម្រេច *លើករណីចៅក្រម ន័យ ថុល*') C11/29 បានដកស្រង់សាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល *លើរឿងក្ដីFurundzija* កថាខណ្ឌ១៩៦ ព្រមទាំងមាត្រា៣.៣ នៃកិច្ចព្រមព្រៀងរវាងអង្គការ សហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលំអៀង និងសុច្ចរិត មានគុណសម្បត្តិដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការងារក្នុងការិយាល័យក្នុងតុលាការនៅក្នុងប្រទេស របស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភព ណាមួយផ្សេងទៀតឡើយ") និងមាត្រា១០ ថ្មីនៃច្បាប់អ.វ.ត.ក ចែងថា "(ចៅក្រមជម្រះក្ដីនៃអង្គជំនុំជម្រះ វិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធី នៃការ ជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលំអៀង និងសុចរិត មាន បទពិសោធន៍ក្នុងការងារជំនាញជាពិសេសខាងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ [...]។ ចៅក្រមជម្រះក្ដី ត្រូវឯករាជ្យ ក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយ ផ្សេងទៀតឡើយ")។

[១២] សេចក្ដីសម្រេច *លើករណីចៅក្រម ន័យ ថុល* កថាខណ្ឌ១៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

លើមូលដ្ឋាននៃការចោទប្រកាន់អំពីភាពលំអៀង ដែលគ្មានមូលដ្ឋាន និងគ្មានសំអាង[13]។ សំណួរដែលសំខាន់ គឺថា តើទស្សនៈនៃកង្វះភាពអនាគតិត្រូវបានធ្វើយុត្តិកម្ម យ៉ាងពិតប្រាកដ ដែរឬទេ[14]។ គ្រាន់តែមានអារម្មណ៍ ឬការសង្ស័យ អំពីភាពលំអៀង ដែលធ្វើដោយជនជាប់ចោទនោះ មិនមានលក្ខណៈគ្រប់គ្រាន់ទេ។ អ្វីដែលចាំបាច់នោះ គឺការយល់ដឹងអំពីភាពលំអៀង យ៉ាងត្រឹមត្រូវជាក់លាក់ ដោយផ្អែកតាមការយល់ដឹងអំពីកាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធ[15]។

៨. ការចោទប្រកាន់អំពីភាពលំអៀង ត្រូវមានការគាំទ្រអំពីមូលដ្ឋានជាក់ស្តែង។ អង្គហេតុដែលគ្រាន់តែថា ចៅក្រមត្រូវបានទិតៀនតាមសារព័ត៌មាននោះ មិនចាំបាច់មានការដកហូតសិទ្ធិរបស់ចៅក្រមនោះទេ[16]។ ទោះបីជាសេចក្តីទុកចិត្តរបស់សាធារណជន អាចត្រូវបានប៉ះពាល់ដោយសារការសន្និដ្ឋាននានា ដែលបានផ្សព្វផ្សាយថា មានភាពលំអៀង ទោះការសន្និដ្ឋាននេះខុសក៏ដោយ ត្រូវក៏ដោយ បណ្តឹងជិតចិត្តមិនបានយកចិត្តទុកដាក់ អំពី"ពាក្យចចាមអារ៉ាម ពាក្យបញ្ជិតបញ្ចៀង ជៀមដាមនិងព័ត៌មានខុស ដែលតាមពិតបានផ្សព្វផ្សាយនៅក្នុងសារព័ត៌មាននានា និងការគំរាមកំហែង ឬការប៉ុនប៉ងបំភ័យចៅក្រមផ្សេងទៀតនោះទេ"[17]។ បញ្ហាផ្សេងៗទៀត ដែលជាធម្មតា មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់លក្ខខណ្ឌដកហូតសិទ្ធិចៅក្រមនោះ គឺ "ការប៉ាន់ប្រមាណ ជំនឿ ការសន្និដ្ឋាន ការសង្ស័យ ការផ្តល់មតិយោបល់

---

១៣ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalic *និងអ្នកផ្សេងទៀត* សាលដីកាអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ សំណុំរឿងលេខ IT-96-21-A កថាខណ្ឌ៧០៧។ ("ទោះបីជាវាមានសារៈសំខាន់ក្នុងការស្វែងរកយុត្តិធម៌ក្តី ប៉ុន្តែវាមានសារៈសំខាន់ដូចគ្នាដែលថា មន្ត្រីតុលាការលាលែងតួនាទីរបស់ខ្លួនក្នុងការជំនុំជម្រះដោយការយល់ព្រមស្រួលៗទៅនឹងការស្នើសុំដោយភាពលម្អៀងជាក់ស្តែង និងមិនលើកទឹកចិត្តដល់ភាគីឲ្យជឿថា តាមរយៈការដាក់បណ្តឹងជំតចិត្តចៅក្រមមួយរូប រឿងក្តីរបស់ពួកគាត់ត្រូវបានជំនុំជម្រះដោយបុគ្គលដែលគិតថា ចៅក្រមរូបនោះទំនងជាសម្រេចលើរឿងក្តីក្នុងផលប្រយោជន៍របស់ខ្លួននោះទេ")។

១៤ សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល *Furundzija* កថាខណ្ឌ ១៨៥។

១៥ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* *Karemera* *និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើបណ្តឹងជិតចិត្តរបស់Joseph Nzirorera ចំពោះចៅក្រម Byron, Kam និង Joensen (ការិយាល័យ) សំណុំរឿងលេខICTR-98-44-T ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ៥។

១៦ *ប្រជាជននៃរដ្ឋIllinois តទល់នឹង* *Alton Coleman* 168 Ill. 2d 509 (1995)។

១៧ *នៅក្នុងករណីសហរដ្ឋអាមេរិក* 666 F.2d 690 (មណ្ឌលទី១ ឆ្នាំ១៩៨១)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ព្រមទាំងបញ្ហាមិនមានភាពជាក់ស្តែងស្រដៀងគ្នានានា” ក៏ដូចជា“របាយការណ៍ នៅក្នុងបណ្តាញផ្សព្វផ្សាយ ដែលអះអាងថាពិត ដូចជាការដកស្រង់ដែលសំដៅដល់ចៅក្រម ឬអ្នកផ្សេងទៀត ប៉ុន្តែដែលតាមពិត គឺខុស ឬតាមពិត គឺមិនត្រឹមត្រូវ ឬដែលនាំឱ្យមានការយល់ខុស”[18]។

៩. តាមទស្សនៈច្បាប់ នៅពេលដែលការចោទប្រកាន់អំពីភាពលំអៀង ត្រូវបានធ្វើឡើងផ្អែកតាមសេចក្តីសម្រេចរបស់ចៅក្រម វាមិនគ្រប់គ្រាន់ក្នុងការដែលគ្រាន់តែចោទប្រកាន់អំពីវិការៈនោះទេ ប្រសិនបើមាន។ អ្វីដែលត្រូវធ្វើការបង្ហាញនោះ គឺថា ការសម្រេចនានាអាចយកមកអនុវត្តបានចំពោះការសម្រេចបញ្ចប់ជាមុនប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង ឬនឹងបានដឹងយ៉ាងសមហេតុផល និងមិនមានការពាក់ព័ន្ធយ៉ាងពិតប្រាកដទៅនឹងការអនុវត្តច្បាប់នោះទេ ដែលអាចនាំឱ្យមានការបកស្រាយដែលអាចមានលើសពីមួយ ឬពាក់ព័ន្ធនឹងការវាយតម្លៃលើអង្គហេតុនានាដែលពាក់ព័ន្ធ[19]។

១០. ផ្អែកតាមអត្ថបទសារព័ត៌មាន ដែលបានរាយការណ៍អំពីសេចក្តីថ្លែងការណ៍ ដែលធ្វើដោយនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា សំណើសុំបានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យមានវិធានការដែលមិនបានគូសបញ្ជាក់ច្បាស់លាស់ ប៉ុន្តែ“សមរម្យ” ដើម្បី“បំភ្លឺ ឬ ត្រួតពិនិត្យ អំពីទង្វើរបស់លោកស្រីចៅក្រម Katinka Lahuis និង លោកចៅក្រម Rowan Downing”[20]។ ដំណោះស្រាយ ដែលបានកំណត់នៅក្នុងវិធាន៣៤នៃវិធានផ្ទៃក្នុង ដែលសំណើសុំបានយកធ្វើជាសំអាង គឺការដិតចិត្តតុលាការ ដែលកំណត់លក្ខខណ្ឌឱ្យភាគីដែលបានប្តឹងដិតចិត្ត ធ្វើការបង្ហាញថា ចៅក្រមដែលកំពុងមានបញ្ហា បានបង្កើតនូវភាពលំអៀង យ៉ាងពិតប្រាកដ។ វិធាននេះបន្តថា អង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើអ្វីទេ ក្នុងករណីដែលបន្ទុកនេះ មិនត្រូវបាន

---

[18] *រឿងក្តី Nichols តទល់នឹង Alley* 71 F.3d 347 (មណ្ឌលទី១០ ឆ្នាំ១៩៩៥)។

[19] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojevic និងអ្នកផ្សេងទៀត* សេចក្តីលើពាក្យសុំរបស់Blagojevic អនុលោមតាមវិធាន ១៥(ខ) (ការិយាល័យ) សំណុំរឿងលេខ IT-02-60 ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ កថាខណ្ឌ១៤។

[20] សំណើសុំ ទំព័រ១។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C. * C.E.T.C.

បំពេញទេនោះ[21]។ អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការ ស្របតាមវិធានផ្ទៃក្នុង ក្នុងការទទួលខុសត្រូវចំពោះតម្រូវការជាទូទៅនេះទេ និងពុំមានអំណាចក្នុងការបង្គាប់ឲ្យមានការស៊ើបសួរទៅលើការចោទប្រកាន់ អំពីភាពលំអៀង ដែលមិនមានភស្តុតាងគាំទ្រគ្រប់គ្រាន់នោះទេ។ ការយល់ឃើញផ្សេងពីនេះ នឹងដកហូតនូវបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការស្វែងរកភស្តុតាង ដែលដាក់លើអ្នកដាក់ពាក្យបណ្តឹង ដែលជាការចាំបាច់ ដើម្បីធ្វើការច្រានចោលនូវការសន្មតទុកជាមុនអំពីភាពអនាគតិនោះ។ ហេតុនេះ ការស្នើរបស់សំណើសុំឲ្យមាន "វិធានការសមរម្យ" ត្រូវបានបដិសេធចោល។

១១. ប្រសិនបើត្រូវបានចាត់ទុកថា ជាបណ្តឹងជំទាស់ចៅក្រមអង្គបុរេជំនុំជម្រះអន្តរជាតិទាំងពីររូបនោះ សំណើសុំនោះមានវិការៈ ដោយសារកង្វះខាតផ្នែកទម្រង់ និងខ្លឹមសារ។ សំណើសុំ បានយោងទៅលើសុន្ទរកថា ដែលធ្វើដោយនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ដែលបានចោទប្រកាន់អំពីអន្តរាគមន៍ធ្វើឡើងដោយរដ្ឋាភិបាលបរទេស ពាក់ព័ន្ធទៅនឹងចៅក្រមអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញទាំងអស់ ប៉ុន្តែ មិនបាននិយាយដល់ទង្វើជាក់លាក់របស់លោកចៅក្រម Downing និងលោកស្រីចៅក្រម Lahuis នោះទេ[22]។ ទោះបីជាបានទទួលស្គាល់ផ្នែកដែលបានរៀបរាប់នៅក្នុងសំណើសុំថា ជាកំណត់ហេតុពិតប្រាកដ នៃសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រីក៏ដោយ ក៏ផ្នែកទាំងនោះមិនមានតម្លៃជាភស្តុតាង ដែលអាចជឿជាក់បាន និងគ្រប់គ្រាន់ដើម្បីបង្ហាញថា ចៅក្រមទាំងពីររូបនេះ មានភាពលំអៀងជាសត្យានុម័ត ឬជាអត្តនោម័តនោះឡើយ។

---

[២១] សេចក្តីសម្រេច*លើករណីចៅក្រម ន័យ ថុល* កថាខណ្ឌ២៨ ("ភាគីមួយដែលតវ៉ានឹងភាពអនាគតិរបស់ចៅក្រម *ត្រូវតែបង្ហាញថា* ចៅក្រមទទួលបានផលប្រយោជន៍បុគ្គលមួយ ឬពាក់ព័ន្ធយ៉ាងពិសេសជាមួយភាគីផ្សេងទៀត") (គូសបញ្ជាក់បន្ថែម)។

[២២] សំណើសុំ កថាខណ្ឌ៨-៩។

១២. នៅក្នុងការអនុវត្តការវិនិច្ឆ័យ ដើម្បីកំណត់សម្រេចថា តើកាលៈទេសៈនានានឹងនាំឲ្យ"អ្នកសង្កេតការណ៍ដ៏សមហេតុផលដែលមានព័ត៌មានគ្រប់គ្រាន់[23]" ឲ្យយល់ដឹងយ៉ាងសមហេតុផលថាមានភាពលំអៀង ដែរឬទេ អង្គបុរេជំនុំជម្រះយល់ឃើញថា អ្នកសង្កេតការណ៍ដ៏សមហេតុផលនិងមានព័ត៌មានគ្រប់គ្រាន់នេះ នឹងធ្វើការពិចារណាលើការធ្វើសច្ចាប្រណិធាន ចូលកាន់តំណែងរបស់ចៅក្រមអង្គបុរេជំនុំជម្រះអន្តរជាតិ និងគុណសម្បត្តិសម្រាប់ការតែងតាំងរបស់ពួកគាត់ ពិចារណាលើចម្លើយតបរបស់ពួកគាត់ទៅនឹងសំណើសុំ ពិចារណាលើចម្លើយតបរបស់អង្គការសហប្រជាជាតិ ទៅនឹងការចោទប្រកាន់របស់សម្តេចនាយករដ្ឋមន្ត្រី នៅពេលនោះ ពិចារណាលើការចង្អុលបញ្ជាក់អំពីការចោទប្រកាន់ទាំងអស់នេះ ព្រមទាំងពិចារណាលើបរិបទនៃការចោទប្រកាន់ទាំងនេះ។

១៣. ផ្ទុយទៅនឹងអ្វី ដែលបានចោទប្រកាន់នៅក្នុងសំណើសុំ[24] អង្គការសហប្រជាជាតិបានធ្វើការបដិសេធជាសាធារណៈចំពោះការចោទប្រកាន់របស់សម្តេចនាយករដ្ឋមន្ត្រី ដូចដែលបានរាយការណ៍នៅក្នុងបណ្តាញព័ត៌មានភ្លាមៗ បន្ទាប់ពីការចេញផ្សាយរបស់ពួកគេ[25]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា ចៅក្រមអន្តរជាតិទាំងពីររូបបានធ្វើសច្ចាប្រណិធានកាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ ថា មិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល

---

២៣ សេចក្តីសម្រេច*លើករណីចៅក្រម ន័យ ថុល* កថាខណ្ឌ២១ ដកស្រង់ពីសាលដីកាអង្គជំនុំជម្រះតុលាការកំពូល*រឿងក្តី Furundzija* កថាខណ្ឌ១៩០។ (*ពិភាក្សា* សំណើសុំ កថាខណ្ឌ២៤ (ប្រៀបធៀប "អ្នកអង្កេតសមហេតុផល និងដឹងព័ត៌មាន" ជាជាង "ប្រជាជនសាមញ្ញ" ដែលគាត់ទំនងជា"លម្អៀងសមហេតុផលយ៉ាងច្បាស់" លើផ្នែកចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះដោយសារតែឋានៈរបស់នាយករដ្ឋមន្ត្រីនៅក្នុងសហគមន៍ ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី)។

២៤ ពាក្យស្នើសុំ កថាខណ្ឌ២៤។

២៥ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ អនុប្រធាននៃការិយាល័យរដ្ឋបាលបានជូនដំណឹងជាផ្លូវការទៅអង្គបុរេជំនុំជម្រះថា បន្ទាប់ពីសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីភ្លាមៗ គាត់បានចេញនូវសេចក្តីថ្លែងជូនទៅសារព័ត៌មានដូចតទៅនេះ៖ "បទដ្ឋានច្បាប់បានបង្កើតយ៉ាងច្បាស់ថា តុលាការមិនបានស្វែងរកការយល់ព្រម ឬការណែនាំលើការងាររបស់ខ្លួនពីផ្នែកប្រតិបត្តិ។ ខ្ញុំគិតថាចៅក្រមអន្តរជាតិអនុវត្តដោយឯករាជ្យពីផ្នែកប្រតិបត្តិ ហើយខ្ញុំគ្មានហេតុផលថា ពួកគេមិនអនុវត្តនោះទេ"។ ("អនុស្សារណៈរបស់អនុប្រធានការិយាល័យរដ្ឋបាលជូនទៅប្រធានអង្គបុរេជំនុំជម្រះចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩")។ *សូមមើល* កាសែត ដឹ ខេមបូឌាដែលី ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ទំព័រ៣១។

ណាមួយ ឬពីប្រភពផ្សេងទៀតនោះឡើយ[26]។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ចៅក្រមទាំងពីររូបលើកឡើងថា ពួកគាត់បានបំពេញតួនាទីយោងតាមការសច្ចាប្រណិធាននេះ ក្នុងខណៈពេលបំពេញការងារជាចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញ ហើយមិនដែលស្វែងរក ឬទទួលយកគោលការណ៍ណែនាំពីរដ្ឋាភិបាលណាមួយឡើយ[27]។ នៅពេលដែលអ្នកសង្កេតការណ៍ដ៏សមហេតុផលនិងមានព័ត៌មានគ្រប់គ្រាន់នឹងពិចារណាថា តើការចោទប្រកាន់ទាំងអស់នេះត្រូវបានចង្អុលបង្ហាញនូវភស្តុតាងដែរឬទេនោះ វាក៏មានការពាក់ព័ន្ធដល់ការកត់សម្គាល់ផងដែរថា គ្មានដំណាក់កាលណា ដែលអង្គជំនុំជម្រះវិសាមញ្ញបានទទួលព័ត៌មានណាមួយពីរាជរដ្ឋាភិបាលកម្ពុជា ដែ លនឹងចង្អុលបង្ហាញ នូវភស្តុតាងស្តីពីកិច្ចអន្តរាគមន៍ ដែលបានលើកឡើង ដែលធ្វើដោយរដ្ឋាភិបាលបរទេសទៅលើចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះនោះទេ ឬជាព័ត៌មានដែលអាចលើកឡើងពីកង្វះឯករាជ្យភាពរបស់តុលាការនោះទេ[28]។

១៤. ជាចុងក្រោយ និងដូចដែលសំណើសុំបានទទួលស្គាល់ សេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី គឺជាការឆ្លើយតបទៅនឹងមតិយោបល់ជំទាស់ដែលធ្វើដោយចៅក្រមអង្គបុរេជំនុំជម្រះអន្តរជាតិទាំងពីររូប ដែលមានប្រសិទ្ធភាពអនុញ្ញាតឲ្យបន្តកិច្ចស៊ើបសួរប្រឆាំងនឹងជនជាប់សង្ស័យថែមទៀតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ[29]។ បន្ថែមពីលើការប៉ាន់ប្រមាណថា

---

[២៦] សេចក្តីសម្រេច*លើករណីចៅក្រម ន័យ ថុល* កថាខណ្ឌ១៨ (កត់សម្គាល់ថា នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦ ចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះរបស់អ.វ.ត.ក ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងបន្ទាប់មកស្បថជាផ្លូវការក្នុងអំឡុងពេលពិធីផ្លូវការមួយ)។

[២៧] ចម្លើយតបរបស់ចៅក្រម Lahuis និង Downing ចំពោះសំណើរបស់លោក អៀង សារី សុំឲ្យមានវិធានការសមរម្យទាក់ទងនឹងសេចក្តីថ្លែងការណ៍មួយចំនួនរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលតតាំងនឹងឯករាជ្យភាព ដែលដាក់ដោយសម្ងាត់នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (“សេចក្តីសន្និដ្ឋានរបស់ចៅក្រម Katinka Lahuis និង Rowan Downing”) កថាខណ្ឌ៩។

[២៨] *សូមមើល* អនុស្សារណៈរបស់អនុប្រធានការិយាល័យរដ្ឋបាលជូនទៅប្រធានអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (“អ.វ.ត.ក មិនបានទទួលជាផ្លូវការ ឬក្រៅផ្លូវការ នូវឯកសារណាមួយដែលគាំទ្រការចោទប្រកាន់ដែលធ្វើឡើងនៅក្នុងសារព័ត៌មាន”)។

[២៩] ពាក្យស្នើសុំ កថាខណ្ឌ ៨។ *ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង* (សំណៅកោសលុបជាសាធារណៈ) ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩។ សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀវ សារី សុំឲ្យមានវិធានការ ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ដែលធ្វើដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

ចៅក្រមអង្គបុរេជំនុំជម្រះអន្តរជាតិទាំងពីររូប បានប្រព្រឹត្តតាមការណែនាំភាគច្រើនពីរដ្ឋាភិបាលរបស់ខ្លួនក្នុងការធ្វើដូច្នោះ សំណើសុំពុំមានបំណងបង្ហាញថា សេចក្តីសម្រេចនេះត្រូវបាន ឬនឹងត្រូវបានយល់ដឹងយ៉ាងសមហេតុផលថា មិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ទេ ដែលនៅក្នុងការសម្រេចនេះអាចមានការបកស្រាយដែលអាចមានលើសពីមួយ ឬមិនទាក់ទងទៅនឹងការវាយតម្លៃលើអង្គហេតុនានាដែលពាក់ព័ន្ធទេ។

១៥. អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំមិនបង្ហាញថា លោកចៅក្រម Downing និងលោកស្រីចៅក្រម Lahuis បានប្រព្រឹត្តតាមការណែនាំរបស់រដ្ឋាភិបាលណាមួយ ឬថាចៅក្រមទាំងនេះមានហេតុផលខាងនយោបាយ នៅពីក្រោយនោះទេ។ វាមិនអាចមានការយល់ឃើញ អំពីកង្វះឯករាជ្យភាពតុលាការ ពីសំណាក់អ្នកសង្កេតការណ៍មិនលំអៀងនោះទេ ដ៏រាបណាអ្នកសង្កេតការណ៍នោះមានព័ត៌មានស្តីពីកាលៈទេសៈនៃបញ្ហាទាំងអស់ ដែលពាក់ព័ន្ធ ដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

យោងលើហេតុផលដូចបានបញ្ជាក់ជូនខាងលើ អង្គបុរេជំនុំជម្រះ សម្រេចជាឯកច្ឆន្ទថា ៖

១. បដិសេធសំណើសុំបើកសវនាការជាសាធារណៈ និងសំណើសុំឮ្យកិច្ចដំណើរការនីតិវិធី

២. សំណើសុំនេះមិនអាចទទួលយកបានដោយគ្មានមូលដ្ឋានត្រឹមត្រូវ និង

៣. ណែនាំឲ្យផ្នែកគ្រប់គ្រងតុលាការធ្វើការចាត់ចំណាត់ថ្នាក់សារជាថ្មី ថាជាឯកសារសាធារណៈចំពោះរាល់ឯកសារទាំងអស់ដែលបានដាក់ជាឯកសារសម្ងាត់ពាក់ព័ន្ធនឹងសំណើសុំនេះ។

អនុលោមតាមវិធាន៣៥(៨) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

00406208

០០២/២០-១០-២០០៩-អវតក/កសចស (អបជ ០៣)

**ធ្វើឡើងដោយអង្គបុរេជំនុំជម្រះ**

ភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Florence MUMBA **ន័យ ថុល** Jean-Marc LAVERGNE **ហួត វុទ្ធី** **ប្រាក់ គីមសាន**

**ប្រាក់ គីមសាន**